# ដំណឹងជ្រើសរើសបុគ្គលិក

មណ្ឌលព័ត៌មានស្ត្រីកម្ពុជាជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ មិនរកប្រាក់ចំណេញ ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយប្រពៃណី និង ទំនើប រួមទាំងកម្មវិធីអប់រំតាមសហគមន៍ ដើម្បីរួមចំណែកលើកស្ទួយសមភាពយេនឌ័រ តួនាទី និង តម្លៃស្ត្រីនៅក្នុងគ្រួសារ សហគមន៍ និងសង្គមជាតិ ។ មណ្ឌលព័ត៌មានស្ត្រីកម្ពុជាត្រូវការជ្រើសរើសបុគ្គលិកចំនួន ១ រូប សម្រាប់មុខដំណែង **មន្ត្រីប្រព័ន្ធផ្សព្វផ្សាយឌីជីថល និង កិច្ចការទំនាក់ទំនង** ។

## ភារកិច្ច

មន្ត្រីប្រព័ន្ធផ្សព្វផ្សាយឌីជីថល និង កិច្ចការទំនាក់ទំនង ទទួលបន្ទុកបណ្តាញផ្សព្វផ្សាយឌីជីថល និង កិច្ចការទំនាក់ទំនង របស់អង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា ។

## ការទទួលខុសត្រូវរបស់មន្ត្រីប្រព័ន្ធផ្សព្វផ្សាយឌីជីថល និង កិច្ចការទំនាក់ទំនង

- ផលិត និង ផ្តល់យោបល់លើខ្លឹមសារ នៃព័ត៌មានឌីជីថលដែលមានគុណភាពខ្ពស់ ដើម្បីផ្សព្វផ្សាយលើគេហទំព័រ និង បណ្តាញសង្គម ខណៈដែលអង្គការកំពុងស្វែងយល់អំពីធនធាន នៃប្រព័ន្ធផ្សព្វផ្សាយចម្រុះ ដើម្បីបង្កើនការទាក់ទាញទស្សនិកជនគោលដៅ និង លើកកម្ពស់សាវតារបស់អង្គការ ។
- បង្កើត និង អនុវត្តយុទ្ធសាស្ត្រទីផ្សារបណ្តាញសង្គមដោយមានប្រសិទ្ធភាព ដើម្បីបង្កើនចំនួនអ្នកតាមដាន អ្នកអាន និង គ្រប់គ្រងគណនីបណ្តាញសង្គម រួមទាំង ការពិភាក្សា និង ការបញ្ចេញមតិ ។
- ត្រួតពិនិត្យ និង លើកកម្ពស់បណ្តាញផ្សព្វផ្សាយឌីជីថលទាំងអស់ ពិសេសប្រព័ន្ធផ្សព្វផ្សាយចម្រុះ នៅក្នុងបរិបទ នៃសម័យឌីជីថលទំនើប ។
- សហការជាមួយនិពន្ធនាយកព័ត៌មាន ដើម្បីផលិតព័ត៌មានឌីជីថល ដូចជា ព័ត៌មានខ្លី ជីវព័ត៌មាន ប្រវត្តិសាស្ត្រ Infographic និង ប្រធានបទជាទីចាប់អារម្មណ៍ផ្សេងទៀត សម្រាប់ផ្សាយប្រចាំថ្ងៃលើអ៊ីនធឺណិត ។
- ស្រាវជ្រាវ និង រៀបចំការសិក្ខាសាលា វេទិកាសាធារណៈ កិច្ចប្រជុំពិចម្ងាយ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណៈជន និង អ្នកពាក់ព័ន្ធ ។
- បង្កើត និង ស្រាវជ្រាវ អំពីបណ្តាញសង្គម ក្នុងគោលបំណងរកប្រាក់ចំណូលតាមប្រព័ន្ធឌីជីថល ។
- ស្រាវជ្រាវអំពីបណ្តាញសង្គម ដោយការសិក្សាទៅលើឥរិយាបទ ការចូលរួមរបស់ទស្សនិកជន ព្រមទាំងដំណើរការ នៃបណ្តាញសង្គមរបស់អង្គការ ។
- គ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា រៀបចំផែនការ អនុវត្ត និង គ្រប់គ្រងបុគ្គលិក ITC ។

- គ្រប់គ្រងកិច្ចការទំនាក់ទំនងសាធារណៈ និង រៀបចំសេចក្តីប្រកាសព័ត៌មានរបស់អង្គការ ។
- គ្រប់គ្រងគម្រោងពាក់ព័ន្ធ ។
- បណ្តុះបណ្តាលបុគ្គលិកអង្គការ និង ស្ថាប័នផ្សេងទៀត ។

**តម្រូវការ និង លក្ខណៈសម្បត្តិ**

- គ្រប់គ្រង និង បង្កើតមាតិកា ខ្លឹមសារព័ត៌មានឌីជីថល់ សម្រាប់បណ្តាញសង្គម ។
- ផលិតព័ត៌មានចម្រុះ រួមមាន វីដេអូ Infographic និង គំនូរជីវចល ។
- ត្រួតពិនិត្យ និង រាយការណ៍អំពីដំណើរការ នៃការផលិតព័ត៌មានឌីជីថល់ ព្រឹត្តិការណ៍ និង យុទ្ធនាការផ្សព្វផ្សាយលើបណ្តាញសង្គម ដោយប្រើឧបករណ៍វិភាគ ។
- រៀបចំ និង សម្រួលការជួបជុំអនឡាញ ដូចជា សិក្ខាសាលា វេទិកាសាធារណៈ ។
- មានទេពកោសល្យ បទពិសោធន៍ ក្នុងការបង្កើតខ្លឹមសារសាមញ្ញ ច្បាស់លាស់ ដោយភាពច្នៃប្រឌិត សម្រួលការទំនាក់ទំនង និង ការលំបាករបស់ទស្សនិកជន ។
- មានសមត្ថភាពក្នុងការគ្រប់គ្រងដោយប្រសិទ្ធភាព និង ធ្វើការនៅក្នុងបរិបទដែលលឿន រហ័ស ។
- មានទំនាក់ទំនងបុគ្គល ការប្រាស្រ័យទាក់ទង និង ភាពជាអ្នកដឹកនាំ
- មានបទពិសោធន៍យ៉ាងតិច ៤ ឆ្នាំ លើផ្នែកឌីជីថល់ និង ទំនាក់ទំនងសាធារណៈ
- មានបទពិសោធន៍ជាអ្នកបច្ចេកទេស អ្នកសរសេរកម្មវិធី អ្នកគ្រប់គ្រងគេហទំព័រ
- មានជំនាញរៀបចំ គ្រប់គ្រង ចាត់ចែងពេលវេលា
- មានទឹកចិត្តធ្វើការងារ ឯករាជ្យ គោលដៅលទ្ធផលច្បាស់លាស់ និង វិជ្ជាជីវៈ
- យ៉ាងហោចណាស់បញ្ចប់សញ្ញាប័ត្រសាកលវិទ្យាល័យ ឬ មហាវិទ្យាល័យសារព័ត៌មាន ឬ ទំនាក់ទំនងអន្តរជាតិ ។
- សញ្ជាតិកម្ពុជា ដែលមានភាសាកំណើតជាភាសាខ្មែរ ។
- ជំនាញទំនាក់ទំនង ជាភាសាអង់គ្លេស (អាន និយាយ ស្តាប់ សរសេរ) ។
- យល់ដឹងទូលំទូលាយអំពី បរិស្ថានសង្គម សេដ្ឋកិច្ច វប្បធម៌ ស៊ីវិល និង នយោបាយ ។
- មានចំណាប់អារម្មណ៍ក្នុងការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយឯករាជ្យប្រកបដោយវិជ្ជាជីវៈ និង ដើម្បីពង្រឹងសមភាពយេនឌ័រនៅកម្ពុជា ។

បេក្ខជន បេក្ខនារីដែលមានចំណាប់អារម្មណ៍ សូមផ្ញើលិខិតបញ្ជាក់អំពីចំណាប់អារម្មណ៍ការងារ និង ប្រវត្តិរូបសង្ខេបដែលមានបិទរូបថតបច្ចុប្បន្ន មកអង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា អាសយដ្ឋានផ្ទះលេខ ២០ ផ្លូវ ២៣ ដេ ភូមិថ្មី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឬ តាមរយៈអ៊ីមែល info@wmc.org.kh ។
ព័ត៌មានលំអិតសូមមើលវេបសាយ https://www.wmc.org.kh និង ទំព័រហ្វេសប៊ុកវិទ្យុស្ត្រី Women's Radio
ទូរសព្ទទំនាក់ទំនង ៖ 023 881 497 /#69 848 013 / 011 780 510
កាលបរិច្ឆេទឈប់ទទួលពាក្យ៖ **ថ្ងៃចន្ទ ទី ៥ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ៥ ល្ងាច ។**

--------------------

អាសយដ្ឋាន ផ្ទះលេខ ២០ ផ្លូវលេខ ២៣ដេ ភូមិថ្មី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។ ប្រអប់សំបុត្រលេខ ៤៩៧
Address: No. 20, Street 23D, Phoumi Thmey, Sangkat Dangkor, Khan Dangkor, Phnom Penh, Cambodia, P.O. Box: 497.
Office Telephone: (855) 23 881 497, Marketing Telephone: (855) 12 202 102/ (855) 15 202 102
Email: info@wmc.org.kh, Website: www.wmc.org.kh, Radio: FM 103.5